**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ១.៧៦០៨ ឧសក.អគក.នបក

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០១៤

# សេចក្ដីជូនដំណឹងលើកចុងក្រោយ

**យោង** ៖ សេចក្ដីប្រកាសជូនដំណឹង លេខ ១៥៥៨ ចុះថ្ងៃទី១៩ កញ្ញា ឆ្នាំ២០១៤ របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្ដីពីលទ្ធផលនៃការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្មឆ្នាំ២០១៤

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំង០៤រូប រួមមាន ៖ លោក **ជន ទាក** , កញ្ញា **ម៉ាន ស្រីមុំ** , លោក **យឹម សិទ្ធិ** , លោក **ភូ សុធារ៉ា** ដែលជាបេក្ខជនប្រឡងជាប់ជាស្ថាពរក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្មឆ្នាំ២០១៤ ឱ្យបានជ្រាបថា គិតមកដល់ពេលនេះ គឺមានរយៈពេល ២៤ថ្ងៃហើយ ដែលលោក និងនាងកញ្ញាមិនបានមកបំពេញសំណុំបែបបទចូលបម្រើការងារទៅតាមលក្ខខ័ណ្ឌកំណត់ក្នុងរយៈពេល ០៧ថ្ងៃ ក្រោយពីថ្ងៃប្រកាសលទ្ធផលប្រឡងជាផ្លូវការ ដូចមានចែងក្នុងសេចក្ដីប្រកាសជូនដំណឹងខាងលើ។ ករណីអវត្តមានដោយគ្មានមូលហេតុបែបនេះ បានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តនីតិវិធី បទប្បញ្ញត្តិ និងគោលការណ៍នៃការរៀបចំក្របខ័ណ្ឌរបស់ក្រសួងឆ្នាំ ២០១៤។

ក្នុងន័យនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមរំលឹកជូនដំណឹងជាលើកចុងក្រោយដល់បេក្ខជនទាំង ០៤រូប ខាងលើ សូមចូលមកបង្ហាញខ្លួនជាបន្ទាន់ នៅនាយកដ្ឋានបុគ្គលិកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅត្រឹមម៉ោង ១៧ម៉០០ **ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ជាកំហិត**។ ផុតរយៈពេលកំណត់លើកចុងក្រោយនេះ ក្រសួងនឹងចាត់វិធានការតាមសេចក្ដីប្រកាសជូនដំណឹង លេខ ១៥៥៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួង ដោយលុបឈ្មោះលោក និងនាងកញ្ញា ចេញពីបញ្ជីបេក្ខជនប្រឡងជាប់ជាស្ថាពរនៃក្របខ័ណ្ឌឆ្នាំ២០១៤ ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិសមស្រប ក្នុងបញ្ជីប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងឆ្នាំ២០១៤ បំពេញបង្គ្រប់ចំនួនក្របខ័ណ្ឌរបស់ក្រសួង ដោយគ្មានការពន្យាពេលតទៅទៀតឡើយ។ ០៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**គឹម ទូច**

**ចម្លងជូន** ៖
- ក្រសួងមុខងារសាធារណៈ
- សាមីជន
- ឯកសារ-កាលប្បវត្តិ

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263